ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបក្រុមបេសកកម្មនៃធនាគារអភិវឌ្ឍន៍អាស៊ី **ADB**



នៅព្រឹកថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបក្រុមបេសកកម្មនៃធនាគារអភិវឌ្ឍន៍អាស៊ី ADB ដឹកនាំដោយ លោក **Eric Sidgwick** នាយកប្រចាំកម្ពុជា នៃធនាគារអភិវឌ្ឍន៍អាស៊ីADB ដើម្បី ពិភាក្សាការងារនៅទីស្តីការក្រសួង ។

លោក **Eric Sidgwick** នាយកប្រចាំកម្ពុជា នៃធនាគារអភិវឌ្ឍន៍អាស៊ី ADB បានលើកបង្ហាញពីបេសកកម្ម ការងាររបស់ធនាគារពិភពលោកនៅកម្ពុជា ក្នុងកម្មវិធីអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ។ ក្នុងនោះ លោកបានលើកឡើងនូវ សសរស្តម្ភចំនួន ០៣ ជាសំខាន់ ដើម្បីជម្រុញកំណើននិងប្រសិទ្ធិភាព គឺការងារគាំទ្រវិស័យកសិកម្ម និង អនាម័យជនបទ– ការអភិវឌ្ឍន៍ធនធានមនុស្ស –និងការគ្រប់គ្រងវិស័យសាធារណៈ និងឯកជន ។ លោក **Eric Sidgwick** បានវាយតម្លៃពី ភាពលូតលាស់ខាងផ្នែកសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា ហើយធនាគារអភិវឌ្ឍន៍អាស៊ី ADB នឹងបន្តធ្វើជាដៃគូសហប្រតិបត្តិការដ៏ល្អជាមួយកម្ពុជា។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងថ្លែងអំណរគុណចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ADB ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងសកម្មភាពអភិវឌ្ឍន៍នៅកម្ពុជា ជាពិសេសនៅក្នុងផែនការអភិវឌ្ឍន៍ យុទ្ធសាស្ត្រជាតិ ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា: ធនាគារ ADB ជាដៃគូអភិវឌ្ឍន៍មួយក្នុងចំណោមដៃគូអភិវឌ្ឍន៍ ចម្បងៗជាច្រើនទៀត ដែលបានផ្តល់ហិរញ្ញប្បទាន ក្នុងការអភិវឌ្ឍន៍វិស័យទឹកស្អាតនៅកម្ពុជា ចាប់តាំងពីឆ្នាំ២០០៤ មក ។ ជាពិសេស នៅឆ្នាំ២០១២ ទៅកន្លងទៅនេះ ធានាគារ ADB បានផ្តល់ហិរញ្ញប្បទានចំនួន **៣៦,៧០លាន** ដុល្លាអាមេរិក សម្រាប់គម្រោងផ្គត់ផ្គង់ទឹកស្អាតនៅតាមទីប្រជុំជន ចំនួន៩ រួមមាន: ខេត្ត ពោធិ៍សាត់ សៀមរាប កំពង់ធំ ស្រុកស្ទោង កំពង់ចាម ស្ទឹងត្រែង ស្វាយរៀង កំពត និងក្រុងព្រះសហនុ ហើយគ្រោងនឹងបញ្ចប់នៅឆ្នាំ២០១៨ ។



ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សន៍លើវិស័យទឹកស្អាត ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបង្ហាញពីការប្តេជ្ញាចិត្ត ដោយឯកឧត្តម បានបញ្ជាក់ថា: បច្ចុប្បន្នក្រសួងបានលើកទឹកចិត្តឱ្យវិស័យឯកជន ចូលរួមវិនិយោគលើវិស័យទឹកស្អាត នៅទីតាំងណា ដែលរដ្ឋមិនទាន់មានលទ្ធភាព ។ ក្នុងនោះក្រសួង បានសម្រេចផ្តល់អជ្ញាប័ណ្ណ ដល់វិស័យឯកជនរហូតដល់រយៈពេល២០ឆ្នាំ និងតម្រូវឱ្យអនុវត្តតាមផែនការដែលក្រសួងបានដាក់ចុះ ដោយធ្វើយ៉ាងណា ឱ្យការអភិវឌ្ឍន៍វិស័យទឹកស្អាត ក្នុងគម្រោងវិនិយោគនីមួយៗ សម្រេចបាន យ៉ាងហោចនូវគោលការណ៍ចំនួន០៣ :គឺគុណភាព សុវត្ថិភាព និងចិរភាព ។ ជាមួយនិងការលើកឡើងពីប្រសិទ្ធិភាព និងសារៈសំខាន់នៃជំនួយហិរញ្ញប្បទានរបស់ធនាគារ ADB លើវិស័យទឹកស្អាតនៅកម្ពុជា ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យធានាគារ ADB បន្តជួយកម្ពុជា បន្ថែមទៀត ជាពិសេសគឺការបណ្តុះបណ្តាលធនធានមនុស្ស និង បំពាក់ឧបករណ៍ពិសោធន៍នៅស្ថានីយ៍ផលិតទឹកស្អាតនីមួយៗ ដើម្បីធ្វើតេស្តពីគុណភាពទឹកដែលត្រូវធ្វើជាប្រចាំ ។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ក៏បានស្នើឱ្យធនាគារ ADB ជួយលើវិស័យការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម ដែលបច្ចុប្បន្ន ការចុះបញ្ជីនេះជាបន្ទុករបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលថ្ងៃអនាគត ការចុះបញ្ជីនេះនឹងដាក់ឱ្យដំណើរការតាមប្រព័ន្ធ Intranet (ប្រព័ន្ធភ្ជាប់បណ្តាញផ្ទៃក្នុង) ។